**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Jul-2013, 09:26
CMS/CFO: Sann Rada

<u>**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**</u>

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៣

<u>**ចំណាត់ថ្នាក់ឯកសារ**</u>

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សេចក្ដីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន**
**ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

កញ្ញា Soumeya MEDJEBEUR

កញ្ញា Vera MANUELLO

កញ្ញា អ៊ួច ស្រីផាត់

កញ្ញា សុគន្ធ ម៉ូនីកា

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន បានបញ្ជូនទៅគ្រប់ភាគីទាំងអស់ នូវកំណត់សម្គាល់របស់ខ្លួនដើម្បីកិច្ចប្រជុំ"ចុងក្រោយ"ស្តីពីការរៀបចំសវនាការដែលបានគ្រោងធ្វើនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣។ នៅក្នុងកំណត់សម្គាល់នោះ ក្រុមមេធាវីការពារក្តីបានធ្វើសំណើទាក់ទិននឹងលក្ខខណ្ឌនៃការសួរដេញដោល លោក ខៀវ សំផន និងការបិទការពិភាក្សាដេញដោលក្នុងសំណុំរឿងបច្ចុប្បន្ន[1]។

២. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ក្នុងអំឡុងនៃកិច្ចប្រជុំរៀបចំសវនាការនោះ ជាបឋម អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចខ្លះៗពាក់ព័ន្ធនឹងចំណុចមួយចំនួន ហើយបន្ទាប់មក ក្រុមមេធាវីការពារក្តីនៅតែបន្តធ្វើ និងបញ្ជាក់ពីសំណើរបស់ខ្លួនដោយផ្ទាល់មាត់។ អង្គជំនុំជម្រះបានសម្រេចដោយផ្ទាល់នៅក្នុងអំឡុងពេលសវនាការ[2] លើសំណើសុំមួយចំនួនក្នុងចំណោមសំណើសុំទាំងនោះ។

៣. បន្ទាប់មក នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ ភាគីទាំងអស់បានទទួលសេចក្តីជូនដំណឹងស្តីពីអនុស្សរណៈមួយរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងលក្ខខណ្ឌនៃការសួរដេញដោលលោក ខៀវ សំផន និងបែបបទនៃការគ្រប់គ្រងក្នុងការបិទកិច្ចពិភាក្សាដេញដោល[3]។

៤. ជាទូទៅ យើងគួរកត់សម្គាល់ថា អង្គជំនុំជម្រះបានបដិសេធរាល់សំណើទាំងនោះ ដែលជាសំណើស្របច្បាប់ និងមានហេតុផលត្រឹមត្រូវ របស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន។ លើសពីនេះទៅទៀត អង្គជំនុំជម្រះ ដែលកាលពីដំបូងបានស្នើសុំឲ្យភាគីទាំងអស់ជម្រាបពីរយៈពេលដែលខ្លួនគិតថាចាំបាច់ក្នុងការតាំងសំណួរទៅកាន់លោក ខៀវ សំផន នោះ (មេធាវីតំណាងដើមបណ្តឹង

---

[1] កំណត់សម្គាល់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/2**។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1**។

[3] *កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1* ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/1/1** ("អនុស្សរណៈ **E288/1/1**") ជូនដំណឹងជាភាសាអង់គ្លេស និងខ្មែរ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ [មេធាវីការពារក្តីធ្វើការងារ ជាមួយសំណៅជាភាសាបារាំងដែលបានផ្តល់ជូនដោយអង្គភាពបកប្រែភាសា]។

រដ្ឋប្បវេណី និង សហព្រះរាជអាជ្ញា បានអនុវត្តតាមសំណើនេះដោយបានជម្រាបជូនពីចំនួនថ្ងៃចាំបាច់សម្រាប់ជនជាប់ចោទនីមួយៗ[4]) ប៉ែរជានៅក្នុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ លោកប្រធានអង្គជំនុំជម្រះបានប្រកាសភ្លាមៗថា ការតាំងសំណួរទៅកាន់ជនជាប់ចោទពុំមានពេលវេលាកំណត់ឡើយ ហើយភាគី និងចៅក្រម អាចសួរសំណួររបស់ខ្លួនបាន ដរាបណាអង្គជំនុំជម្រះគិតថាជាសំណួរពាក់ព័ន្ធ[5]។

៥. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ចាត់ទុកថាការបដិសេធបែបនេះបានរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិជាមូលដ្ឋានរបស់កូនក្តីខ្លួន។ នៅក្នុងបរិបទនេះ លោក ខៀវ សំផន ត្រូវបង្ខំចិត្តសុំឲ្យសម្រេចលើសិទ្ធិទាំងនេះដែលលោកទំនងជាអាចត្រូវទទួលបាន រួមមាន សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបរហូតដល់ការបិទបញ្ចប់"កិច្ចពិភាក្សាដេញដោល" និងសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយបន្ទាប់ពីសេចក្តីសន្និដ្ឋានការពារ។

## I- ការពិនិត្យសំណើសុំរបស់ លោក ខៀវ សំផន

៦. ចាប់តាំងពីពេលដំបូងនៃការជំនុំជម្រះមក លោក ខៀវ សំផន តែងតែបានប្រកាសថា ដោយអនុលោមតាមគោលការណ៍សច្ចាធារណ៍និរទោស និងបន្ទុកក្នុងការស្វែងរកភស្តុតាងដែលជាតួនាទីរបស់សហព្រះរាជអាជ្ញា លោកអាចនឹងឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគីទាំងអស់ល្គឹកណាភស្តុតាងទាំងអស់ត្រូវបានបង្ហាញ។

៧. ដោយការបញ្ចប់ដំណាក់កាលទីមួយនៃការជំនុំជម្រះកាន់តែខិតជិតមកដល់ហើយនោះ លោក ខៀវ សំផន បានប្រកាសពីឆន្ទៈរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគីទាំងអស់។ ដោយលោកមានអាយុកាន់តែច្រើន អង្គហេតុក៏បានកើតឡើងជាយូរមកហើយ ហើយ

---

[4] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីពេលវេលាដែលត្រូវការសម្រាប់សួរសំណួរជនជាប់ចោទ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/1,** អ៊ីមែលរបស់មេធាវី SIMONNEAU-FORT ដែលមានចំណងជើងថា៖ « *Information Re Planning of upcoming hearings* » ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ១៤ និង ៤៩ នាទី។

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២៩ បន្ទាត់ ១៩-៥២ និងទំព័រ ៣០ បន្ទាត់ ១-៤ (ភាសាបារាំង)។

រឿងក្តីបច្ចុប្បន្នក៏មានឯកសារច្រើនសម្បើមដែរនោះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន បានធ្វើសំណើមួយចំនួនដែលត្រូវបានគេកត់សម្គាល់ថា សំណើបែបនេះជាការអនុវត្តជាទូទៅនៅចំពោះមុខតុលាកាឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់ ហើយជាពិសេសទៅទៀតនោះ គឺជាសំណើដែលមានហេតុផលត្រឹមត្រូវ។ អាស្រ័យហេតុនេះ លោក ខៀវ សំផន បានស្នើសុំ៖

– ពីភាគីទាំងអស់ និងពីអង្គជំនុំជម្រះ នូវបញ្ជីសំណួររៀបតាមប្រធានបទដែលខ្លួនចង់សួរ[6]។
– ពីភាគីទាំងអស់ និងពីអង្គជំនុំជម្រះ នូវបញ្ជីឯកសារដែលខ្លួនចង់យកមកប្រើប្រាស់ក្នុងការតាំងសួរសំណួរទៅកាន់រូបលោក ដោយបានបញ្ជាក់ថាបញ្ជីទាំងនោះមានគោលបំណងជួយឱ្យលោក ខៀវ សំផន អាចអាននូវឯកសារទាំងនោះនៅមុនពេលសវនាការ ហើយសូមឱ្យបញ្ជីទាំងនោះមិនត្រូវមានភាពលម្អិតខ្លាំងពេកនោះទេ ដោយត្រូវស្ថិតក្នុងសមាមាត្រមួយដែលសមរម្យ[7]។
– ពេលត្រៀមចំនួនបីសប្តាហ៍ដោយពុំមានសវនាការ ដែលនឹងត្រូវស្ថិតនៅក្នុងចន្លោះពេលនៃការបញ្ចប់ការបង្ហាញភ័ស្តុតាង និងការសួរសំណួរទៅកាន់រូបលោក ហើយរយៈពេលស្នើសុំនេះត្រូវចាប់គិតពីពេលដែលបានទទួលបញ្ជីដែលស្នើសុំខាងលើ[8]។
– អនុញ្ញាតឱ្យមេធាវីរបស់លោកអាចចូលទៅក្នុងមន្ទីរឃុំឃាំងបាននៅក្នុងថ្ងៃចុងសប្តាហ៍[9]។
– ឱ្យការតាំងសំណួរទៅរូបលោកក្នុងអំឡុងពេលសវនាការធ្វើឡើងតែកន្លះថ្ងៃ និងនៅពេលព្រឹកដែលជាពេលវេលាដែលសមត្ថភាពផ្ចង់អារម្មណ៍របស់លោកមានលក្ខណៈប្រសើរ[10]។

៨. ជាមួយគ្នានឹងការស្នើសុំនេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ក៏បានរំលឹកអង្គជំនុំជម្រះថាខ្លួនមានការលំបាកផ្លូវច្បាប់ដែលមិនត្រូវបានដោះស្រាយ ហើយដែលបានបង្កជាភាពមិនច្បាស់លាស់ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ លោក ខៀវ សំផន នៅពេលដែលរូបលោកត្រៀមខ្លួនឆ្លើយទៅ

---

[6] កំណត់សម្គាល់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/2** កថាខណ្ឌ ៦។

[7] ដូចយោងខាងលើ។

[8] ដូចយោងខាងលើ កថាខណ្ឌ ៧, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤២ បន្ទាត់ ៣-៧ (ភាសាបារាំង)។

[9] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤២ បន្ទាត់ ៩-១១ (ភាសាបារាំង)។

[10] កំណត់សម្គាល់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/2** កថាខណ្ឌ ៦។

នឹងសំណួរនានា។ ការលំបាកនេះពាក់ព័ន្ធជាពិសេសនឹងការប្រើប្រាស់ភស្តុតាងដែលប្រមូលបាននៅក្នុងការជំនុំជម្រះបច្ចុប្បន្នសម្រាប់រឿងក្តីនាពេលអនាគត (រួមទាំងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនៅក្នុងសវនាការ)[11]។ ដោយឡែក ការលំបាកនេះពិតជាធ្ងន់ធ្ងរសម្រាប់ លោក ខៀវ សំផន បើទោះបីជាលោកបានទទួលរងនូវការលំបាកភ្ជាប់មកជាមួយនឹងវ័យរបស់លោកយ៉ាងណាក៏ដោយ (ការឆាប់អស់កម្លាំង និងការលំបាកក្នុងការផ្តង់អារម្មណ៍) ក៏លោកមិនមានរោគសញ្ញាណាមួយដែលអាចអនុញ្ញាតឲ្យវាយតម្លៃពីភាពមិនច្បាស់លាស់នៃការបន្តជីវិតរបស់លោកសម្រាប់ការជំនុំជម្រះបច្ចុប្បន្ន និងនាពេលអនាគតឡើយ។

៩. អង្គជំនុំជម្រះបានបដិសេធសំណើទាំងអស់នោះក្នុងរបៀបមួយដែលមិនអាចយល់បាន។ បើទោះបីជាអង្គជំនុំជម្រះបានស្នើឲ្យភាគីទាំងអស់ *"ជូនដំណឹងឲ្យបានទាន់ពេលវេលាទៅភាគីផ្សេងៗ និងអង្គជំនុំជម្រះ នូវឯកសារនានាដែលពួកគាត់អាចដេញដោលជនជាប់ចោទនាពេលសវនាការ"* ដោយបានបញ្ជាក់ថា *"អង្គជំនុំជម្រះក៏នឹងជូនដំណឹងទៅភាគីអំពីឯកសារនានាដែលខ្លួនត្រូវយកមកប្រើប្រាស់សម្រាប់គោលបំណងនេះផងដែរ"*[12] ក៏អង្គជំនុំជម្រះមិនបានធ្វើការបង្ហាញណាមួយទាក់ទិននឹងរយៈពេលកំណត់នៃការបញ្ជូន និងចំនួនឯកសារទាំងអស់នោះដែរ។ អង្គជំនុំជម្រះមិនបានឆ្លើយតបទាល់តែសោះទៅនឹងសំណើសុំទាក់ទិននឹងការជូនដំណឹងស្តីពីបញ្ជីសំណួរតាមប្រធានបទ ការរៀបចំកម្មវិធីសួរសំណួរនៅពេលព្រឹក និងសំណើសុំអនុញ្ញាតឲ្យមេធាវីការពារក្តីអាចចូលមន្ទីរឃុំឃាំងបាននៅថ្ងៃចុងសប្តាហ៍។ អង្គជំនុំជម្រះបានបដិសេធសំណើសុំរយៈពេលត្រៀមចំនួនបីសប្តាហ៍ដោយគ្មានសវនាការ ក្រោមមូលហេតុថានីតិវិធីនៅក្នុងសំណុំរឿង ០០២ បានដំណើរការអស់ពេលវេលាជាងបួនឆ្នាំមកហើយ និងការជំនុំជម្រះអស់រយៈពេល ១៨ ខែ។ ផ្អែកតាមហេតុផលនេះ អង្គជំនុំជម្រះយល់ថា *"ជនជាប់ចោទ និងមេធាវីរបស់គាត់មានពេលគ្រប់គ្រាន់សម្រាប់ដឹងឲ្យបានពេញលេញពីប្រភេទនៃបទចោទប្រកាន់ប្រឆាំងនឹងរូបគាត់"*[13]។

១០. ខាងក្រោមនេះ យើងនឹងមើលឃើញថាសំណើសុំរបស់មេធាវីការពារក្តី ពិតជាមានហេតុផលត្រឹមត្រូវ និងមានភាពស្របច្បាប់ ប្រាសចាករាល់ចារិតពន្យារកិច្ចដំណើរការជំនុំជម្រះ។

---

[11] ដូចយោងខាងលើ កថាខណ្ឌ ១០, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៤២ បន្ទាត់ ១២-១៧ (ភាសាបារាំង)។

[12] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ៣០ បន្ទាត់ ១០-១៦ (ភាសាបារាំង)។

[13] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៩។

## ១. សំអាងហេតុនៃសំណើសុំ

១១. ដូចគ្នាទៅនឹងសាក្សីវ័យចំណាស់មួយចំនួន ដែលបានមកផ្តល់សក្ខីកម្មដែរ លោក ខៀវ សំផន ដែលមានអាយុ ៨២ ឆ្នាំ លែងមានរូបរាងកាយ ការចងចាំ និងសមត្ថភាពក្នុងការផ្តង់អារម្មណ៍ដូចបុរសពេញកម្លាំងទៀតហើយ។ ផ្ទុយទៅវិញ លោកត្រូវការពារខ្លួនទល់នឹងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ស្មុគស្មាញ និងសម្រាប់អង្គហេតុដែលបានកើតឡើងកាលពី ៤០ ឆ្នាំមុន។

១២. ម្យ៉ាងវិញទៀត យើងសូមរំលឹកថា ស្ថានភាពរបស់ជនជាប់ចោទគឺខុសគ្នាពីស្ថានភាពរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនានា ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងដំណើរការជំនុំជម្រះ (ដោយអ្នកទាំងនោះបានទទួលជាមុននូវឯកសារដើម្បី"រំលឹកការចងចាំរបស់ពួកគាត់" និង/ឬ ប្រសិនបើជាអ្នកជំនាញវិញ គឺត្រូវផ្តល់ជូនពួកគាត់នូវបញ្ជីប្រធានបទដែលអាចត្រូវបានលើកឡើងនៅក្នុងពេលចូលខ្លួនរបស់ពួកគាត់)។ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ថា "*ជនជាប់ចោទជាមនុស្សទទួលរងបទចោទប្រកាន់*"ដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានបដិសេធ និង"*ជាអ្នកដែលប្រសើរបំផុតក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនោះ*" ដូច្នេះតម្រូវឲ្យមានការសួរសំណួររយៈពេលយូរ និង "*ឲ្យបានស៊ីជម្រៅ*"[14]។

១៣. ក្នុងវ័យនេះ លោក ខៀវ សំផន មិនអាចទ្រាំទ្របានទៅនឹងសំណួរដ៏ច្រើនសន្ធឹកសន្ធាប់ជាប់គ្នាក្នុងរយៈពេលដ៏ខ្លីបានទេ បើទោះបីជាសំណួរទាំងនោះអាចមានលក្ខណៈរំលោភបំពានខ្លះក៏ដោយ ព្រោះថានាពេលថ្មីៗនេះ អង្គជំនុំជម្រះមិនមានប្រតិកម្មអ្វីទាល់តែសោះក្នុងការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មើលងាយសាក្សីដោះបន្ទុកមួយរូប[15]។

---

[14] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីពេលវេលាដែលត្រូវការសម្រាប់សួរសំណួរជនជាប់ចោទ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/1** កថាខណ្ឌ ១០ និង ១១។

[15] សូមមើល ជាអាទិ៍៖ ប្រតិចារឹកសវនាការ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/205.1** ទំព័រ ១០១-១០៦ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/206.1** ទំព័រ ៣៣ បន្ទាត់ ៧-១២ ទំព័រ ៤៤ បន្ទាត់ ១១-១៥ (ភាសាបារាំង), ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/210.1** ទំព័រ ១១ បន្ទាត់ ១-១០ (ភាសាបារាំង)។

១៤. វិធានការណ៍ដែលស្នើសុំដោយមេធាវីការពារក្ដីពិតជាមានសំអាងហេតុត្រឹមត្រូវជាងនេះទៅទៀត ព្រោះថាសំណួរដែលនឹងត្រូវចោទសួរទៅកាន់ លោក ខៀវ សំផន អាចនឹងឃ្លាតចេញឆ្ងាយយ៉ាងខ្លាំងពីវិសាលភាពនៃសំណុំរឿងទីមួយ ក្រោមហេតុផលថាមានភាពពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ឬ រចនាសម្ព័ន្ធរដ្ឋបាលដែលជាចំណុចដែលសហព្រះរាជអាជ្ញាបានប្រកាសថាខ្លួនមានបំណងពិនិត្យឲ្យបាន "*ល្អិតល្អន់*" និង "*ស៊ីជម្រៅ*"[16]។

១៥. ម្យ៉ាងវិញទៀត យើងគួរគូសបញ្ជាក់ថា មេធាវីសព្វថ្ងៃរបស់ លោក ខៀវ សំផន បានចូលមកកាន់សំណុំរឿងក្រោយពេលចាប់ផ្ដើមការជំនុំជម្រះទៅហើយ ហើយខ្លួនមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការងារត្រៀមរៀបចំកូនក្ដីរបស់ខ្លួនឡើយ ព្រោះពួកគាត់ត្រូវស្វែងយល់ពីសំណុំរឿង និងគ្រប់គ្រងសវនាការ[17]។

១៦. ដូច្នេះ ចាប់ពីពេលចូលមកកាន់សំណុំរឿងមក-ដោយមានការពិគ្រោះយោបល់ជាមួយកូនក្ដី ការងាររបស់ក្រុមមេធាវីការពារក្ដីបានផ្ដោតទាំងស្រុងលើការរៀបចំសវនាការ និងការពិនិត្យបញ្ហានីតិវិធី និងគតិយុត្តិដែលមានភាពប្រែប្រួលដូចគ្នាទៅនឹងការកំណត់ពីវិសាលភាពនៃការជំនុំជម្រះ (ខណៈដែលការជំនុំជម្រះបានចាប់ផ្ដើមទៅហើយនោះ) ឬកាតព្វកិច្ចដែលតម្រូវឲ្យមេធាវីការពារក្ដីដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅពេលដែលការជំនុំជម្រះមិនទាន់ត្រូវបានបញ្ចប់។

១៧. លើសពីនេះទៅទៀត ដោយអង្គជំនុំជម្រះមិនអាចផ្ដល់កាលវិភាគ នៃការចូលខ្លួនឲ្យបានលើសពីពីរសប្ដាហ៍មុន និងបានកែប្រែលេខរៀងនៃការចូលខ្លួនដោយមិនបានជូនដំណឹងជាមុន និងបានកែប្រែអត្តសញ្ញាណសាក្សីដែលត្រូវបានកោះហៅនោះ ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន មិនអាចរៀបចំពេលធ្វើការងារជាមួយកូនក្ដីរបស់ខ្លួនបានទេ ក្រៅតែពីត្រូវសម្របតាមកម្មវិធីផ្លាស់ប្ដូរសាក្សី។ បរិបទបែបនេះមិនបានអនុញ្ញាតឲ្យមានការត្រៀមរៀបចំឲ្យបានត្រឹមត្រូវឡើយ។

---

[16] សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីពេលវេលាដែលត្រូវការសម្រាប់សួរសំណួរជនជាប់ចោទ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/1** កថាខណ្ឌ ៤ និង ៥។

[17] មេធាវី គង់ សំអុន ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវី Arthur VERCKEN ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវី Anta GUISSÉ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២។ អ្នកគ្រប់គ្នាបានដឹងហើយថា មេធាវី Jacques VERGÈS ដែលមានអាយុច្រើនជាងជនជាប់ចោទទៀតនោះ មិនបានចូលរួមក្នុងសវនាការ តាំងពីខែមករា ឆ្នាំ ២០១២ មកម្ល៉េះ។

១៨. ម្យ៉ាងវិញទៀត បើផ្អែកតាមតារាងពេលវេលា និងថ្ងៃធ្វើការរបស់មន្ទីរឃុំឃាំងដែលបិទនៅថ្ងៃចុងសប្តាហ៍នោះ[18] ភាគច្រើននៃកិច្ចពិភាក្សារបស់ លោក ខៀវ សំផន និងមេធាវីរបស់គាត់ គឺត្រូវបានកំណត់មកត្រឹមតែរយៈពេលបីម៉ោងនៅព្រឹកថ្ងៃសុក្រប៉ុណ្ណោះ (ប្រសិនបើមិនចំថ្ងៃឈប់សម្រាកបុណ្យ)។

១៩. ចាប់តាំងពីខែ សីហា ឆ្នាំ ២០១២ មក មេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងអំពីការលំបាកនេះ ដោយបានស្នើឱ្យអង្គជំនុំជម្រះផ្តល់លទ្ធភាពបន្ថែមទៀតដល់ខ្លួនក្នុងការចូលក្នុងមន្ទីរឃុំឃាំង។ ដោយទទួលស្គាល់ថា *"ត្រូវតែមានការធានាមួយដល់ក្រុមមេធាវីការពារក្តី ដើម្បីអាចមានលទ្ធភាពជួបជាមួយកូនក្តីរបស់ខ្លួនរៀងៗខ្លួន"* អង្គជំនុំជម្រះបានសន្យាថានឹងជូនដំណឹងដល់ភាគីអំពីផ្នែកបន្តបន្ទាប់នៃសំណើសុំនេះ "នាពេលវេលាសមស្របមួយ"[19]។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះពុំដែលបានអនុវត្តតាមការសន្យានោះឡើយ។

២០. ជាសរុបមក សំណើសុំទាំងឡាយដែលបានដាក់ដោយមេធាវីការពារក្តីលោក ខៀវ សំផន សុទ្ធតែមានសម្អាងហេតុពេញលេញ។ យើងនឹងឃើញជាបន្តទៀតថា សំណើសុំទាំងនោះពុំមានគោលដៅពន្យារពេលកិច្ចដំណើរការនីតិវិធីសោះឡើយ។

## ២. <u>សំណើសុំដែលពុំមានគោលដៅពន្យារពេលកិច្ចដំណើរការនីតិវិធី</u>

២១. តាំងពីចាប់ផ្តើមកិច្ចដំណើរការជំនុំជម្រះក្តី មេធាវីការពារក្តីលោកណ ខៀវ សំផន អាចមានលទ្ធភាពស្នើសុំឱ្យមានការព្យួរកិច្ចដំណើរការនីតិវិធី ឬលើកការបើកសវនាការលើអង្គសេចក្តីបានដើម្បីអាចឱ្យមេធាវីថ្មីក្នុងក្រុមរបស់ខ្លួនធ្វើការសិក្សាលើសំណុំរឿងបានសព្វជ្រុងជ្រោយ។ ប៉ុន្តែក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពុំបានស្នើសុំដូច្នោះឡើយ។ នៅក្នុងអំឡុង និងនាពេលបញ្ចប់ការជំនុំជម្រះលើសំណុំរឿងទីមួយ មេធាវីការពារក្តីលោក ខៀវ សំផន អាចមានលទ្ធភាពបន្តនីតិវិធីដែលជ្រើសរើសដោយសហព្រះរាជអាជ្ញា គឺការធ្វើបណ្តឹងសារទុក្ខទៅនឹងសេចក្តី

---

[18] ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង ៨ និង ៣០ នាទី ដល់ម៉ោង ១១ និង ៣០ នាទី និងពីម៉ោង ១៤ ដល់ម៉ោង ១៧ លើកលែងថ្ងៃឈប់សម្រាកបុណ្យ។

[19] ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E1/114.2** ទំព័រ ៥២ បន្ទាត់ ១៣-២៥ និងទំព័រ ៥៣ បន្ទាត់ ១-៩ (ភាសាបារាំង)។

សម្រេចបំបែកសំណុំរឿង[20]។ ប៉ុន្តែមេធាវីការពារក្តីពុំបានប្តឹងសារទុក្ខឡើយ។ មិនតែប៉ុណ្ណោះ មេធាវីការពារក្តីអាចស្នើសុំឲ្យមានការកោះហៅសាក្សីបន្ថែម[21] មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទៀត។ ប៉ុន្តែមេធាវីការពារក្តីក៏ពុំបានស្នើសុំដែរ។

២២. មេធាវីការពារក្តីលោក ខៀវ សំផន តែងតែទទូចសុំជានិច្ចឲ្យកិច្ចដំណើរការជំនុំជម្រះក្តីប្រព្រឹត្តទៅបានឆាប់រហ័ស។ អ្វីដែលមេធាវីការពារក្តីបានស្នើសុំ គឺដើម្បីធានាថា មេធាវីការពារក្តីអាចមានលទ្ធភាពជាក់ស្តែង ដើម្បីត្រៀមការពារក្តីនាដំណាក់កាលចុងក្រោយនានានៃសំណុំរឿងទីមួយ ដោយមិនធ្វើឲ្យយឺតយ៉ាវដល់ដំណើរការជំនុំជម្រះនោះ[22]។

២៣. ដំណាក់កាលចុងក្រោយនៃការជំនុំជម្រះលើសំណុំរឿងទីមួយ គឺជាដំណាក់កាលដែលសំខាន់ជាងគេបំផុត។ ដំណាក់កាលទាំងនោះគឺជាដំណាក់កាលចំបងនៃកិច្ចពិភាក្សាដេញដោល ដោយហេតុថា ក្នុងដំណាក់កាលទាំងនេះ ភាគីនីមួយៗអាចដាក់សារណាការពាររបស់ខ្លួនបានដោយផ្អែកលើរាល់ឯកសារភស្តុតាងទាំងឡាយដែលត្រូវបានដេញដោលក្នុងអំឡុងពេលសវនាការ។

២៤. ដោយឡែក អង្គជំនុំជម្រះមិនត្រឹមតែបានបដិសេធដល់មេធាវីការពារក្តី មិនឲ្យត្រៀមរៀបចំដើម្បីតតាំងទៅនឹងការតាំងសំណួរ ប្រកបដោយភាពថ្លៃថ្នូរ យុត្តិធម៌ និងដោយសន្តិវិធី ប៉ុន្តែអង្គជំនុំជម្រះថែមទាំងបានអូសបន្លាយពេលវេលានៃការតាំងសំណួរលើជនជាប់ចោទ ឲ្យដល់កម្រិតអតិបរិមាទៀត។

---

[20] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/1**, *បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២* ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/2/1**។

[21] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ សុំឲ្យផ្តល់ព័ត៌មានមុនកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E288/3**។

[22] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ១២ បន្ទាត់ ៦-១៤ (ភាសាបារាំង)។

### ៣. សំណើសុំដែលមានលក្ខណៈសមហេតុសមផល

២៥. សំណើសុំឲ្យមានលក្ខខណ្ឌត្រៀមរបស់មេធាវីការពារក្ដី មានលក្ខណៈសមហេតុសមផលណាស់ ក្នុងកាលៈទេសៈពិសេសនៃការជំនុំជម្រះរឿងក្ដីដែលមានលក្ខណៈស្មុគស្មាញនេះ ខណៈដែលជនជាប់ចោទមានវ័យជាង ៨០ ឆ្នាំ ទៅហើយ មិនតែប៉ុណ្ណោះ អង្គហេតុដែលត្រូវបានចោទប្រកាន់ បានកន្លងផុតទៅអស់រយៈពេល ៤០ ឆ្នាំ មកហើយនោះ។

២៦. សំណើសុំរបស់មេធាវីការពារក្ដីពុំមានលក្ខណៈជ្រុលហួសហេតុនោះទេ បើផ្អែកទៅលើការអនុវត្តជាក់ស្ដែងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា (ដែលជនជាប់ចោទមានវ័យក្មេងជាង ហើយអង្គហេតុដែលត្រូវបានចោទប្រកាន់ ទើបនឹងកើតឡើងថ្មីៗនោះ)។ ជាឧទាហរណ៍ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ឧទាហរណ៍ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង MPAMBARA ឬរដ្ឋអាជ្ញា ទល់នឹង KALIMANZIRA) ជនជាប់ចោទដែលសម្រេចឆ្លើយតបទៅនឹងការចោទសួររបស់ភាគី និងចៅក្រម មានរយៈពេលពីមួយទៅពីរសប្ដាហ៍ ដើម្បីត្រៀមរៀបចំឆ្លើយសំណួរ ដោយពុំមានសវនាការឡើយក្នុងរយៈពេលនោះ មិនតែប៉ុណ្ណោះ ពួកគេមានលទ្ធភាពជួបជាមួយមេធាវីការពារក្ដីរបស់ខ្លួនបានគ្រប់ពេលវេលា រួមទាំងថ្ងៃចុងសប្ដាហ៍ទៀតផង។ ដោយឡែក នៅក្នុងសំណុំរឿងដែលបានលើកជាឧទាហរណ៍នេះ សវនាការលើអង្គសេចក្ដីបានប្រព្រឹត្តទៅអស់រយៈពេលប្រហែល ២ ខែ ប៉ុណ្ណោះ ហើយឯកសារដែលបានដាក់ជាភស្តុតាងក្នុងសំណុំរឿង មានចំនួនតែជាង ១០០ ទំព័រ ប៉ុណ្ណោះ។

២៧. សំណើសុំរបស់មេធាវីការពារក្ដីលោក ខៀវ សំផន មានលក្ខណៈសមហេតុសមផលពិតប្រាកដឆ្លើយតបទៅនឹងថិរវេលាដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីតាំងសំណួរលើរូបលោក ខៀវ សំផន។ ជាក់ស្ដែង រយៈពេល ៣ សប្ដាហ៍ ដែលគ្មានសវនាការ (ពី ១៥ ព្រឹក ដល់ ២១ ព្រឹក អាស្រ័យទៅលើថា តើមេធាវីជនជាប់ចោទអាចនឹងមានលទ្ធភាពទូលំទូលាយថែមទៀតក្នុងការចូលទៅមន្ទីរឃុំឃាំង ឬអត់) គឺជារយៈពេលអប្បបរិមាមួយសម្រាប់ត្រៀមរៀបចំការផ្ដល់ចម្លើយយ៉ាងហោចណាស់ ៤ សប្ដាហ៍ និងប្រហែលជាទ្វេដង

ប្រសិនណាជាយើងបន្ថែមរយៈពេលតាំងសំណួររបស់ចៅក្រម និងរបស់មេធាវីការពារក្តីខ្លួនឯងផ្ទាល់[23]។

២៨. ដោយឡែក ខណៈដែលអង្គជំនុំជម្រះបានសម្រេចថា ថិរវេលានៃការតាំងសំណួរលើជនជាប់ចោទទាំងពីរមិនអាចកម្រិតបាន[24] សំណើសុំពីដំបូងរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ត្រូវបានមើលឃើញថាមានលក្ខណៈមិនគ្រប់គ្រាន់ ឬអាចនិយាយបានថាស្តួចស្តើងគួរឲ្យអស់សំណើច។

២៩. ជាក់ស្តែង សំណើសុំដែលបានដាក់ គួរតែត្រូវបានពិនិត្យឡើងវិញឲ្យបានសព្វជ្រុងជ្រោយជាចាំបាច់ ដើម្បីធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ ជាក់ស្តែង ការបដិសេធសំណើសុំដែលស្នើឲ្យមានការផ្តល់រយៈពេល ៣ សប្តាហ៍ សម្រាប់ត្រៀមរៀបចំឆ្លើយសំណួរ ដោយពុំមានការធ្វើសវនាការ ដោយហេតុថា នីតិវិធីក្នុងសំណុំរឿង ០០២ បានអូសបន្លាយអស់រយៈពេលជាង ៤ ឆ្នាំ ហើយការជំនុំជម្រះបានអូសបន្លាយអស់រយៈពេល ១៨ ខែ មកហើយ ហេតុដូច្នេះហើយ *"ជនជាប់ចោទ និងមេធាវីរបស់ខ្លួន មានពេលវេលាគ្រប់គ្រាន់ ដើម្បីអាចយល់បានច្បាស់អំពីប្រភេទនៃបទចោទដែលខ្លួនត្រូវធ្វើការឆ្លើយតប"*[25] ការច្រានចោលនេះពុំមានមូលដ្ឋានសម្អាងទាល់តែសោះ។

៣០. មេធាវីការពារក្តីលោក ខៀវ សំផន សូមធ្វើការប្រឆាំងដាច់ខាតទៅនឹងសម្អាងហេតុដ៏ខុសឆ្គងនេះ។ ជាក់ស្តែង ចាប់តាំងពីពេលដំបូងនៃការជំនុំជម្រះ (និងចាប់តាំងពីពេលមេធាវីការពារក្តីលោក ខៀវ សំផន បានមកដល់) សិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានការជូនដំណឹងអំពីភ័ស្តុតាងដាក់បន្ទុកទៅលើពួកគេ ក្នុងក្របខណ្ឌនៃសំណុំរឿងទីមួយ ត្រូវបានគេមើលស្រាលយ៉ាងខ្លាំង។ វិសាលភាពនៃសំណុំរឿងទីមួយមិនត្រឹមតែបានបង្កើតជាភាពមិនច្បាស់លាស់ ភាពប្រែប្រួល និងភាពច្រលំបល់ តាំងពីពេលចាប់ផ្តើមដំបូងប៉ុណ្ណោះទេ ប៉ុន្តែបច្ចុប្បន្នស្ថានភាពនេះនៅតែកើតមានដដែល។ ជាមួយគ្នានេះ ប៉ុន្មានសប្តាហ៍មុនពេលមានការបិទសវនាការលើអង្គសេចក្តី សេចក្តី

---

[23] ពេលវេលាយ៉ាងតិចណាស់ ១២ ព្រឹក សម្រាប់សហព្រះរាជអាជ្ញា (**E288/3**) និងយ៉ាងតិចណាស់ ២ ព្រឹក សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី [(ឯកសារ **E1/207.1** ទំព័រ ៣៨ បន្ទាត់ ៩-១២ (ភាសាបារាំង)] ក្នុងរយៈពេលសវនាការ ៤ សប្តាហ៍ ដែលក្នុងមួយសប្តាហ៍ មានសវនាការ ៤ ព្រឹក។

[24] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២៩ បន្ទាត់ ១៩-២៥ និងទំព័រ ៣០ បន្ទាត់ ១-៤ (ភាសាបារាំង), អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៨។

[25] អនុស្សរណៈ **E288/1/1** កថាខណ្ឌ ៩។

សម្រេចបំបែកសំណុំរឿងត្រូវបានប្ដឹងឧទ្ធរណ៍[26] មេធាវីការពារក្ដីនៅតែពុំទាន់បានកំណត់ជាស្ថាពរ អំពីខ្លឹមសារនៃរឿងក្ដីបច្ចុប្បន្ននៅឡើយ។ មេធាវីការពារក្ដីក៏ពុំទាន់បានកំណត់អំពីខ្លឹមសារពាក់ព័ន្ធ ទៅនឹងបែបផែននៃការទទួលខុសត្រូវ (ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ដែលស្ថិតនៅក្រៅ វិសាលភាពនៃសំណុំរឿងទីមួយនៅឡើយដែរ[27]។ មេធាវីការពារក្ដីក៏ពុំទាន់ត្រូវបានជូនដំណឹងអំពី បែបផែនដែលសំណុំរឿងទីមួយត្រូវបានគេប្រើប្រាស់ជា *"មូលដ្ឋានទូទៅមួយ ដើម្បីពិនិត្យលើ អង្គហេតុទាំងមូលដែលចោទប្រកាន់លើជនជាប់ចោទ រួមទាំងអង្គហេតុទាំងឡាយដែលត្រូវជំនុំ ជម្រះក្នុងសំណុំរឿងក្រោយៗទៀត"*[28] និងអំពីបញ្ហាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារ ភ័ស្តុតាង ព្រមទាំងសេចក្ដីសន្និដ្ឋាននានាលើសំណុំរឿងទីមួយ ក្នុងក្របខណ្ឌនៃរឿងក្ដីបន្ទាប់ទៀត។

## II. ជនជាប់ចោទដែលមិនអាចបញ្ចេញមតិបាន ត្រូវបង្ខំចិត្តនៅស្ងៀម

៣១. នៅខណៈពេលដែលអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចដូចបានលើកឡើងខាងលើនេះ អង្គជំនុំជម្រះបានកម្រិតដែនកំណត់ដែលមានលក្ខណៈមិនសមហេតុសមផលទាល់តែសោះ ពាក់ព័ន្ធទៅនឹងទំហំនៃសារណាបញ្ចប់ និងសេចក្ដីសន្និដ្ឋានការពារបញ្ចប់[29]។ អង្គជំនុំជម្រះក៏មិនបានឆ្លើយតប ទៅនឹងសំណើសុំផ្សេងៗទៀតរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ទាក់ទងនឹងការបកប្រែ និងការបំភ្លឺលើឯកសារ E3។

---

[26] *បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរស្ដីពីការបំបែកកិច្ចដំណើរនីតិវិធីនៃ សំណុំរឿង ០០២* ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/2/1**, *បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេច លើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្ដឹងសាទុក្ខរបស់ សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី* ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/4/1**, *សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ* អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៩។

[27] ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ សំណៅព្រាង ទំព័រ ៣៦-៥៣ (ភាសាបារាំង)

[28] ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E131** កថាខណ្ឌទីបី ទំព័រ ២-៣។

[29] ដូចយោងខាងលើ កថាខណ្ឌ ១០ និង ១១។

៣២. ក៏ប៉ុន្តែ សេចក្តីសម្រេចទាំងអស់របស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការរៀបចំបិទសវនាការលើសំណុំរឿងនេះ ត្រូវបានគេវិភាគឃើញថាជាការហាមឃាត់មិនឱ្យមេធាវីការពារក្តីធ្វើការដេញដោលលើឯកសារភ័ស្តុតាងទាំងមូលដែលបានដាក់ដោយភាគីក្នុងអំឡុងពេលនៃការជំនុំជម្រះ។

៣៣. ជាក់ស្តែង ដោយពុំគិតទៅដល់បញ្ហាគតិយុត្តិដែលត្រូវបានព្យួរមួយអន្លើ ការពិភាក្សាដេញដោលលើសារណាបញ្ចប់ចំនួន ១០០ ទំព័រ និងការការពារក្តីរយៈពេល ២ ថ្ងៃ លើឯកសារចំនួន ៦ ៣០០ ឯកសារដែលមានលេខសម្គាល់ E3[30] និងឯកសារផ្តល់សក្ខីកម្មចំនួន ៩៣ របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី (ដោយមិនទាន់គិតដល់ការផ្តល់សក្ខីកម្មពីសំណាក់ជនជាប់ចោទដែលត្រូវធ្វើដោយគ្មានកំណត់ថិរវេលាផង)[31] មិនអាចធ្វើទៅបានឡើយ និងជារឿងមួយដែលមិនត្រឹមត្រូវទាល់តែសោះ។

៣៤. ទោះបីជាមានសំណើសុំជាច្រើនរបស់មេធាវីការពារក្តី ដែលស្នើឱ្យមានការបន្ថែមចំនួនទំព័រសម្រាប់សារណាបញ្ចប់ ដែលចំនួននេះគួរតែត្រូវបានបង្កើន ដោយសារមានមូលហេតុសមស្របពាក់ព័ន្ធនឹងការកើនឡើងនៃចំនួនសាក្សីដែលចូលមកផ្តល់សក្ខីកម្ម និងចំនួនឯកសារដែលបានដាក់ចូលក្នុងកិច្ចពិភាក្សា ព្រមទាំងបន្ទាប់មានជនជាប់ចោទម្នាក់បានទទួលមរណភាព អង្គជំនុំជម្រះនៅតែមានះរក្សាការកម្រិតចំនួនទំព័រដូចដែលបានកំណត់ពីមុនមក។ យើងកត់សម្គាល់ឃើញថាក្នុងការសម្រេចយ៉ាងដូច្នេះ អង្គជំនុំជម្រះបានផ្តល់អត្ថប្រយោជន៍ដល់សហព្រះរាជអាជ្ញាដែលអាចរក្សាចំនួនទំព័រនៃសារណារបស់ខ្លួន ២០០ ទំព័រ ដដែល ទោះបីជា ចំនួនជនជាប់ចោទបានថយចុះក៏ដោយ។

---

[30] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/207.1** ទំព័រ ២៩ បន្ទាត់ ៤-១៧ (ភាសាបារាំង) (៤០០០ + ១៥០០ និង ៨០០)។

[31] ត្រឹមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ សាក្សីចំនួន ៨៧ នាក់ បានមកផ្តល់សក្ខីកម្ម + សាក្សីបន្ថែមចំនួន ៥ នាក់ទៀត (*អ៊ីមែលរបស់លោកស្រី* Susan LAMB *ផ្ញើជូនភាគី កម្មវត្ថុ៖ Advance notification of additional witnesses to be summoned in Case 002/01 in response to the parties' requests at the Final TMM* ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E292**) + Steven Heder (អ៊ីមែលរបស់លោក CRIPPA កម្មវត្ថុ៖ *« Updated Schedule for upcoming weeks (1-11 July 2013) »* ដែលបានផ្ញើជូនភាគី នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ១០ និង ៤៦ នាទី។

៣៥. ជាក់ស្តែង វាច្បាស់ណាស់ថា "កិច្ចពិភាក្សាដេញដោល" ត្រូវបានបិទរួចទៅហើយ ហើយអង្គជំនុំជម្រះពុំចាប់អារម្មណ៍ទៅលើអ្វីដែលមេធាវីការពារក្តីមានបំណងលើកឡើងនោះឡើយ។

៣៦. ការណ៍ដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចទាំងអស់នេះ ហើយបដិសេធចោលសំណើសុំរបស់មេធាវីការពារ វាគឺជាសិទ្ធិរបស់លោក ខៀវ សំផន សិទ្ធិដែលត្រូវតែធានាដល់លោក ខៀវ សំផន ដោយយោងទៅលើគោលការណ៍គតិយុត្តិទាំងឡាយដែលអនុវត្តនៅ អ.វ.ត.ក.។

៣៧. យោងទៅលើគោលការណ៍ដែលគេហៅថា "គោលការណ៍ជាសារវន្ត"[32] លោក ខៀវ សំផន ត្រូវតែបានទទួលស្គាល់ថា មានសិទ្ធិទទួលបានពេលវេលាដើម្បីត្រៀមការពារខ្លួនលោក ដោយមានជំនួយពីមេធាវីរបស់លោក និងមានសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងដោយគោរពគោលការណ៍ចំពោះមុខ ដែលអនុញ្ញាតឲ្យមេធាវីរបស់គាត់អាចធ្វើការជំទាស់ទៅនឹងសារណារបស់ភាគីដទៃទៀត ព្រមទាំងអាចដេញដោលទៅលើឯកសារភស្តុតាងទាំងឡាយដែលបានដាក់នៅចំពោះមុខចៅក្រម។

៣៨. ដោយឡែក អ្វីដែលសំខាន់គឺថា លោក ខៀវ សំផន ត្រូវបានបង្ខំឲ្យធ្វើការត្រៀមរៀបចំតតាំងទៅនឹងការតាំងសំណួរជាមួយមេធាវីរបស់លោក ហើយមេធាវីរបស់លោក ខៀវ សំផន ត្រូវបានរារាំងមិនឲ្យធ្វើការដេញដោលលើឯកសារភស្តុតាងទាំងមូល ដែលដាក់បន្ទុកលើកូនក្តីរបស់ខ្លួន។ ការការពារក្តីបែបនេះពុំមែនជាការការពារក្តីប្រកបដោយប្រសិទ្ធិភាពនោះទេ ពោលគឺគ្រាន់តែធ្វើឲ្យល្អមើលតែប៉ុណ្ណោះ។

៣៩. នៅក្នុងលក្ខខណ្ឌបែបនេះ វាហាក់ដូចជានៅក្នុងតុលាការមួយនេះ មេធាវីការពារក្តីគ្រាន់តែជាឧបករណ៍សម្រាប់លម្អបន្ទប់កញ្ចក់មួយនេះ (ហើយជាពិសេស នៅពេលដែលក្បាលមីក្រូពុំត្រូវបានកាត់ផ្តាច់ដោយលោកប្រធានអង្គជំនុំជម្រះ...) ក្នុងគោលបំណងតែមួយគត់ គឺដើម្បីធ្វើឲ្យដំណើរការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌប្រព្រឹត្តទៅដោយស្របច្បាប់នោះ។

---

[32] វិធាន ២១ នៃវិធានផ្ទៃក្នុង, សូមមើលផងដែរ៖ មាត្រា ១៤ (៣) នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៣១ និង ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៣ (១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (A/RES/57/228B), មាត្រា ៣៥ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៤០. នៅក្នុងលក្ខខណ្ឌដូចនេះ ហើយទោះបីជាលោក ខៀវ សំផន មានឆន្ទៈតាំងពីដំបូងក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគីក៏ដោយ ក៏លោក ខៀវ សំផន នឹងមិនធ្វើការឆ្លើយសំណួរនោះឡើយ។ លោក ខៀវ សំផន នឹងធ្វើតែសេចក្ដីថ្លែងការណ៍នាចុងបញ្ចប់នៃការជំនុំជម្រះប៉ុណ្ណោះ[33]។

## ហេតុដូច្នេះ

៤១. មេធាវីការពារក្ដីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា **ចាត់វិធានការ** ដោយហេតុថាលោក ខៀវ សំផន នឹងមិនធ្វើការឆ្លើយតបទៅនឹងសំណួរដែលចោទសួរដោយចៅក្រម និងភាគី ហើយលោក ខៀវ សំផន នឹងធ្វើតែសេចក្ដីថ្លែងការណ៍នាចុងបញ្ចប់នៃការជំនុំជម្រះតែប៉ុណ្ណោះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ<br><br>ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[33] វិធាន ៩៤ (១) និង (៣) នៃវិធានផ្ទៃក្នុង, ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្ដុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E288** កថាខណ្ឌ ៦។